# មេរៀនទី៩៖ ព្រះយេស៊ូវបង្រៀននៅក្នុងសាលាប្រជុំ

## លូកា ៤៖១៤-២១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/Do_eMR9Ug7s

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/md7tomLKpOk

**គោលបំណង៖** ព្រះយេស៊ូវជួយដល់មនុស្សដែលរងទុក្ខ

**ខគម្ពីរចងចាំ៖ យ៉ាកុប ៥:១៣** *"តើមានពួកអ្នករាល់គ្នាណា កើតទុក្ខលំបាកឬទេ ត្រូវឲ្យអ្នកនោះអធិស្ឋាន តើមានអ្នកណាអរសប្បាយឬទេ ត្រូវឲ្យគេច្រៀងសរសើរដល់ព្រះចុះ"*

**ចំរៀង** ( *យូធូបលីង* )៖

១. សរសើរព្រះយេស៊ូវ https://youtu.be/uA448Ncse8Q

២. ហូសាណានៅឋានខ្ពស់បំផុត https://youtu.be/QWQ47zCVaCw

៣. ពេលព្រះវិញ្ញាណបរិសុទ្ធ https://youtu.be/RODHIMCRzw4

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត « **គូររូបមុខក្រៀមក្រំ** »



សំភារៈដែលត្រូវការ៖ បោះពុម្ពក្រដាសដែលមានតែទម្រង់មុខ (សូមមើលនៅទំព័រខាងក្រោម)

១. ពេលកុមារដើរចូលមកក្នុងថ្នាក់រៀន សូមហុចក្រដាសទៅឲ្យពួកគេ ហើយឲ្យពួកគេគូររូបមុខពួកគេ នៅពេលដែលពួកគេមិនសប្បាយចិត្ត តើមុខរបស់គេមើលទៅយ៉ាងម៉េច?

២. សូមឲ្យកុមារគូររូបលើក្រដាសតែម្ខាងបានហើយ ហើយឲ្យពួកគេទុកក្រដាសម្ខាងទៀត។ (យើងនឹងប្រើក្រដាសម្ខាងទៀតសំរាប់ធ្វើហត្ថកម្ម)

### ៤. ការណែនាំមេរៀន

តើប្អូនធ្លាប់យំដែរឬទេ?ហេតុអ្វីបានជាប្អូនយំ?( *ទុកឲ្យកុមារឆ្លើយ* ) មានពេលជាច្រើនដែលយើងមានអារម្មណ៍ថាសោកសៅ ឬកើតទុក្ខ។ ពេលដែលយើងមានអារម្មណ៍បែបនេះ យើងអាចនឹងគិតថាយើងកំពុងតែនៅឯកា។ ថ្ងៃនេះយើងនឹងរៀនពីព្រះយេស៊ូវជាអ្នកដែលដឹងពេលដែលយើងយំដោយសារតែភាពសោកសៅ ឬកើតទុក្ខ ហើយនឹងរបៀបដែលទ្រង់ជួយយើងនៅពេលដែលយើងឈឺចាប់។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវបានធ្វើដំណើរជុំវិញស្រុកភូមិដើម្បីបង្រៀន និងប្រោសមនុស្ស។ មនុស្សជាច្រើនបានឮពីព្រះនាមទ្រង់។ ថ្ងៃមួយ ពេលព្រះយេស៊ូវយាងទៅសាលាប្រជុំក្នុងស្រុកកំណើតរបស់ទ្រង់ ដែលជាទីក្រុងតូចមួយឈ្មោះណាសារ៉ែត។ សាលាប្រជុំប្រៀបដូចជាព្រះវិហារ ជាទីកន្លែងដែលជនជាតិយូដាទៅថ្វាយបង្គំព្រះ។ ប្រជាជននៅទីនោះមានចិត្តរំភើប ដោយសារពួកគេធ្លាប់បានស្គាល់ព្រះយេស៊ូវ តាំងពីទ្រង់នៅក្មេង ហើយពួកគេក៏បានឮ ពីការអស្ចារ្យទាំងប៉ុន្មានដែលទ្រង់បានធ្វើផងដែរ។ ព្រះយេស៊ូវបានក្រោក

ឡើងក្នុងសាលាប្រជុំ ហើយបើកគម្ពីរទៅក្នុងកំណ្ឌគម្ពីរអេសាយ។ ទ្រង់បានអានព្រះបន្ទូលទាំងនេះ។ (សូមបោះពុម្ព និងបង្ហាញខគម្ពីរខាងក្រោម)

**អេសាយ ៦១៖១-៣** "ព្រះវិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ា ទ្រង់សណ្ឋិតលើខ្ញុំ ពីព្រោះព្រះយេហូវ៉ាទ្រង់បាន
ចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្សទាល់ក្រ ទ្រង់បានចាត់ខ្ញុំឲ្យមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង និងប្រកាសប្រាប់ពីសេចក្ដីប្រោសលោះដល់ពួកឈ្លើយ ហើយពីការដោះលែងដល់ពួកអ្នកដែលជាប់ចំណង។ ព្រមទាំងប្រកាសប្រាប់ពីឆ្នាំ ដែលព្រះយេហូវ៉ាទ្រង់សព្វព្រះហឫទ័យ និងពីថ្ងៃដែលព្រះនៃយើងខ្ញុំនឹងសងសឹកផង ហើយឲ្យកំសាន្តចិត្តនៃអស់អ្នកណាដែលសោយសោក។ នឹងចែកឲ្យដល់ពួកអ្នកដែលសោយសោក នៅក្រុងស៊ីយ៉ូនបានភួងលំអជំនួសផេះ ហើយប្រេងនៃសេចក្ដីអំណរជំនួសសេចក្ដីសោកសៅ ព្រមទាំងអាវពាក់នៃសេចក្ដីសរសើរ ជំនួសទុក្ខធ្ងន់ដែលគ្របសង្កត់ ដើម្បីឲ្យគេបានហៅថា ជាដើមឈើនៃសេចក្ដីសុចរិត គឺជាដើមដែលព្រះយេហូវ៉ាបានដាំ មានប្រយោជន៍ឲ្យទ្រង់បានថ្កើងឡើង។"

បន្ទាប់ពីព្រះយេស៊ូវអានចប់ មនុស្សទាំងអស់រងចាំមើល ថាព្រះអង្គនឹងមានបន្ទូលអ្វីទៀត **លូកា ៤៖២១** ប្រាប់យើងថា " ទ្រង់ចាប់តាំងមានព្រះបន្ទូលទៅគេថា នៅថ្ងៃនេះ បទគម្ពីរនេះបានសំរេចនៅត្រចៀកអ្នករាល់គ្នាហើយ " ។

ពេលដែលមនុស្សបានឮបែបនេះ ពួកគេមានការភ្ញាក់ផ្អើល។ ព្រះយេស៊ូវមានបន្ទូលថា ទ្រង់គឺជាម្នាក់ដែលបានសន្យា ហើយបានសរសេរនៅក្នុងគម្ពីរអេសាយប្រហែលជា៧០០ឆ្នាំមុន។ ទ្រង់គឺជាព្រះអង្គសង្គ្រោះព្រះមេស៊ី ជាអ្នកដែលប្រោសមនុស្សខ្វាក់ និងរំដោះអ្នកដែលត្រូវគេជិះជាន់ឲ្យរួច។ ទ្រង់គឺជាអ្នកដែលជួយដល់អ្នកដែលយំសោកដោយសារតែភាពសោកសៅ និងមានទុក្ខព្រួយ។

ព្រះគម្ពីរបានប្រាប់យើងថាពេលដែលព្រះយេស៊ូវរស់នៅលើផែនដី ទ្រង់បានយំជាមួយសម្លាញ់របស់ទ្រង់ពេលដែលពួកគេសោកសង្រេង។ ពេលដែលមាននរណាម្នាក់យំជាមួយយើង យើងមានអារម្មណ៍ថាដូចជាត្រូវបានលួងលោម ហើយភាពសោកសៅបន្តិចបន្តួចរបស់យើងក៏សាយបាត់ទៅ។ ព្រះយេស៊ូវទ្រង់ជ្រាបនៅពេលដែលយើងកើតទុក្ខ។ ទ្រង់ជួយដល់មនុស្សដែលមានទុក្ខព្រួយ ហើយព្រះអង្គនឹងកំសាន្តចិត្ត ហើយផ្ដល់នូវសន្តិភាពដល់យើង។

## ៦. សំនួរពិភាក្សា

១. តើកន្លែងដែលជនជាតិយូដាទៅថ្វាយបង្គំឈ្មោះអ្វី? (*សាលាប្រជុំ*)

២. តើព្រះគម្ពីរអ្វីដែលព្រះយេស៊ូវយកមកអាននៅក្នុងសាលាប្រជុំ? (*ព្រះគម្ពីរអេសាយ*)

៣. តើហេតុអ្វីបានជាមនុស្សមានការភ្ញាក់ផ្អើល? (*ព្រះយេស៊ូវមានបន្ទូលថា ទ្រង់គឺជាព្រះមេស៊ីដែលពិពណ៌នានៅក្នុងគម្ពីរអេសាយ*)

៤. តើអ្នកអាចធ្វើអ្វីបានខ្លះពេលដែលអ្នកយំ? (*ទូលសូមព្រះយេស៊ូវឲ្យទ្រង់បាន កំសាន្តចិត្តយើង ត្រូវការអ្នកណាម្នាក់អោប ឬលួងលោមអ្នក, ឬក៏ត្រូវការការនៅជិតម្ដាយ របស់អ្នក*)។

## ៧. ល្បែងកំសាន្ត « ឆ្លងកាត់ឧបសគ្គ »

សំភារៈត្រូវការមានដូចជា កៅអី តុ ក្រមា ធុងទឹក ដុំថ្ម(តាមស្ថានភាពទីតាំង)

១. យើងបែងចែកកុមារជា២ក្រុម

២. ក្រុមនីមួយត្រូវរើសម្នាក់ៗមកដើម្បី ចងរុំភ្នែករបស់គេជាមួយនឹងក្រមា



៣. យើងត្រូវ យកសំភារៈ មកដាក់ពាសពេញថ្នាក់រៀនធ្វើជាឧបសគ្គ
៤. បន្ទាប់មកឲ្យកុមារដែលត្រូវគេចង់ភ្នែកនោះ ដើរឆ្លងកាត់ឧបសគ្គទាំងឡាយ ដោយសមាជិកក្រុមនីមួយៗត្រូវស្រែកប្រាប់អ្នកដែលត្រូវបិទភ្នែកនោះថា (ត្រូវហើយ, ដើររៀង ,ដើរកន្លង ,លូន ទៅឆ្វេង ទៅស្តាំ ទៅមុខ... )។
សូមពន្យល់កុមារថា ការជួយគ្នាឲ្យឆ្លងពីទីតាំងម្ខាងទៅទីតាំងម្ខាងទៀតនៅក្នុងថ្នាក់ ដោយមិនជាន់នៅលើឧបសគ្គណាមួយនោះ នឹងជួយឲ្យយើងបានសម្រេចនូវគោលដៅយ៉ាងពិតប្រាកដ។

**៨. ខគម្ពីរចងចាំ**

**យ៉ាកុប ៥:១៣** “ *តើមានពួកអ្នកណាល់គ្នាណា កើតទុក្ខលំបាកឬទេ ត្រូវឲ្យអ្នកនោះអធិស្ឋាន តើមានអ្នកណាអរសប្បាយឬទេ ត្រូវឲ្យគេច្រៀងសរសើរដល់ព្រះចុះ*” ។

**៩. ហាត្ថកម្ម** « **គូររូបមុខរីករាយ** »



ក. ប្រាប់កុមារយកមុខក្រៀមក្រំដែលគេបានគូរនៅពេលចាប់ផ្តើមរៀនចេញមក
ខ. គ្រូពន្យល់កុមារៈ យើងបានរៀនរួចមកហើយថា នៅពេលដែលយើងសោកសៅ ឬកើតទុក្ខ ព្រះយេស៊ូវនឹងកំសាន្តចិត្តយើង។
គ. ប្រាប់កុមារឲ្យត្រឡប់ក្រដាសរបស់ពួកគេទៅខាងខ្នង(ខាងទំព័រទទេរ) ដោយឲ្យគូរនូវទឹកមុខរបស់ពួកគេ ថានឹងទៅជាបែបណានៅពេលដែលព្រះយេស៊ូវបានកំសាន្តចិត្តពួកគេ។

**១០. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូៈ** (**សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន**)
សូមអានព្រះគម្ពីរ **លូកា ៤៖១៨-២១**។ ដែលបានប្រាប់យើងថា ព្រះយេស៊ូបានអានព្រះគម្ពីរអេសាយ ហើយទ្រង់មានបន្ទូលថា ទ្រង់គឺជាព្រះមេស្ស៊ី ដែលគម្ពីរអេសាយបានពណ៌នា។ តើអ្នកគិតថាមនុស្សទាំងអស់ដែលអង្គុយនៅសាលាប្រជុំនឹងមានប្រតិកម្មដូចម្តេចនៅពេលបានឮបែបនេះ? មានមនុស្សជាច្រើនមិនសប្បាយចិត្តពេលដែលឮព្រះយេស៊ូមានបន្ទូលថាទ្រង់ជាព្រះមេស្ស៊ី។ សូមឲ្យយើងបានអធិស្ឋានអរព្រះគុណដល់ព្រះ ដែលធ្វើឲ្យអ្នកបានជឿលើព្រះយេស៊ូវដែលជាព្រះមេស្ស៊ី។ ហើយសូម អធិស្ឋានឲ្យកូនសិស្សដែលអ្នកនឹងបង្រៀនដូចគ្នា ដើម្បីឲ្យពួកគេជឿលើព្រះយេស៊ូវ ដែលជាព្រះមេស្ស៊ីរបស់ពួកគេផងដែរ។



អេសាយ ៦១:១-៣ “ព្រះវិញ្ញាណនៃព្រះអម្ចាស់យេហូវ៉ា ទ្រង់សណ្ឋិតលើខ្ញុំ
ពីព្រោះព្រះយេហូវ៉ាទ្រង់បានចាក់ប្រេងតាំងខ្ញុំឲ្យផ្សាយដំណឹងល្អដល់មនុស្ស
ទាល់ក្រ ទ្រង់បានចាត់ខ្ញុំឲ្យមក ដើម្បីនឹងប្រោសមនុស្សដែលមានចិត្តសង្រេង
និងប្រកាសប្រាប់ពីសេចក្ដីប្រោសលោះដល់ពួកឈ្លើយ ហើយពីការដោះលែងដល់
ពួកអ្នកដែលជាប់ចំណង។ ព្រមទាំងប្រកាសប្រាប់ពីឆ្នាំ ដែលព្រះយេហូវ៉ាទ្រង់សព្វ
ព្រះហឫទ័យ និងពីថ្ងៃ ដែលព្រះនៃយើងខ្ញុំនឹងសងសឹកផង ហើយឲ្យកំសាន្ត
ចិត្តនៃអស់អ្នកណាដែលសោយសោក។ នឹងចែកឲ្យដល់ពួកអ្នកដែលសោយ
សោក នៅក្រុងស៊ីយ៉ូនបានភួងលំអជំនួសផេះ ហើយប្រេងនៃសេចក្ដីអំណរ
ជំនួសសេចក្ដីសោកសៅ ព្រមទាំងអាវពាក់នៃសេចក្ដីសរសើរ ជំនួសទុក្ខធ្ងន់ដែល
គ្របសង្កត់ ដើម្បីឲ្យគេបានហៅថា ជាដើមឈើនៃសេចក្ដីសុចរិត គឺជាដើមដែល
ព្រះយេហូវ៉ាបានដាំ មានប្រយោជន៍ឲ្យទ្រង់បានថ្កើងឡើង។”